# អារម្ភបទ

រឿងភោគកុលកុមារ អ្នកឧកញ៉ាព្រះឃ្លាំង នង បាននិពន្ធជាពាក្យកាព្យក្នុងពុទ្ធសករាជ ២៣៤៧ មហាសករាជ ១៧២៦ ចុល្លសករាជ ១១៦៦ គ្រិស្តសករាជ ១៨០៤ ក្នុងរជ្ជកាលព្រះបាទអង្គចន្ទទី ២ ។

សេចក្ដីក្នុងរឿងនេះ មានទំនងជាជាតកមួយ ដូចជាតកទាំងពួងដែរ តែមិនសង្គ្រោះចូលក្នុង ៥០ ជាតក ( បញ្ញាសជាតក ) ឬក្នុងរឿង ៥០០ ជាតក ( ជាតកដ្ឋកថា ) ទេ ។ ប្រហែលជារឿងនេះ ជាជាតកមួយដោយឡែក ក្រៅពីក្រុមជាតកទាំងឡាយ ដូចជាលោកនយជាតក ដែលពុទ្ធសាសនបណ្ឌិត្យបានបោះពុម្ពចេញជាសៀវភៅហើយ ហៅថា លោកនយប្បករណ៍ ។ នៅវេលាដែលកំពុងចម្លងផ្ទៀងផ្ទាត់រឿងនេះ យើងមិនទាន់បានឃើញច្បាប់ជាតកបាលីនៅឡើយទេ ប្រទះឃើញតែច្បាប់សម្រាយ ជាស្នាដៃរបស់អ្នកឧកញ៉ាព្រះឃ្លាំង នង នេះប៉ុណ្ណោះ តែយើងសន្និដ្ឋានថា អ្នកឧកញ៉ាព្រះឃ្លាំង នង ប្រាកដជាប្រែចេញពីច្បាប់ជាតកបាលី ហើយរៀបរៀងជាពាក្យកាព្យឡើង មិនមែនប្រឌិតតែងឡើងដោយខ្លួនលោកទេ ។

សម័យបុរាណ គ្រប់តែវត្ត អារាមនៅប្រទេសកម្ពុជាយើងទាំងមូល បានយកសាស្ត្រាភោគកុលកុមារនេះ ជាកម្មវិធីសិក្សាអក្សរសាស្ត្រខ្មែរ ដើម្បីឲ្យកុលបុត្រអ្នកសិក្សាអក្សរ បានចេះដឹងនូវវណ្ណគតិអក្សរសាស្ត្រ និងគតិលោក គតិធម៌ ។

យើងបានចម្លងរឿងនេះចេញពីសាស្ត្រាស្លឹករឹតរបស់ បណ្ណាល័យនៃ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយា ពីឆ្នាំ ១៩៤៨ មុនរួចហើយ ប៉ុន្តែដោយឃើញថា រឿងនេះ ជារឿង ទាក់ទងដោយគតិលោក និងគតិធម៌ ជាវណ្ណគតិខាងអក្សរសាស្ត្រ ជាតិមួយ មានសម្ពួសព្រាក្យកាព្យពិរោះពីសាគួរចាប់អារម្មណ៍ក្រៃពេកផង ហើយត្រូវតាមកម្មវិធីសិក្សារបស់ក្រសួងអប់រំជាតិផង ទើបបានចម្លងចេញ ពីទស្សនាវដ្ដីកម្ពុជសុរិយានោះ ផ្ទៀងផ្ទាត់បោះពុម្ពផ្សាយជាសៀវភៅមួយ ដាច់ដោយឡែកឡើង ។

ការពិនិត្យផ្ទៀងផ្ទាត់នេះ យើងបានតម្កល់ទុកសាច់រឿងនិងពាក្យ កាព្យឲ្យនៅតាមច្បាប់ដើម គ្រាន់តែតម្រូតម្រង់ពាក្យពេចន៍ខ្លះ ដែល យល់ឃើញថាគក់ ដោយការចម្លងត ៗ គ្នាជាច្រើនតំណមកហើយ និង ប្រើអក្សរតាមវចនានុក្រមខ្មែរនាសម័យបច្ចុប្បន្នប៉ុណ្ណោះ ។



យើងសង្ឃឹមថា សៀវភៅរឿងភោគកុលកុមារនេះ នឹងបានជា កម្លាំងមួយ ក្នុងការពង្រីកអក្សរសាស្ត្រជាតិ ឲ្យមានវឌ្ឍនាការជា ភិយ្យោភាពតទៅអនាគតជាពុំខាន ។

ពុទ្ធសាសនបណ្ឌិត្យ

# ប្រវត្តិសង្ខេបនៃឧកញ៉ាព្រះឃ្លាំង ងង

ថ្ងៃ-ខែ-ឆ្នាំកំណើត, ស្រុកកំណើតនិងនាមមាតាបិតា នៃឧកញ៉ាព្រះឃ្លាំង ងង យើងមិនអាចដឹងបាន តាំងកាលដែលលោកនៅពីកុមារបានសិក្សាអក្សរសាស្ត្រ និងបួសនៅវត្តណា ក៏មិនអាចដឹងបានដែរ ព្រោះស្រាវជ្រាវរកពុំឃើញ ។ យើងដឹងបានតែត្រង់លោកបួសហើយបានរៀនគាថាបាលីព្រះត្រៃបិដក ចេះដឹងជ្រៅជ្រះ ហើយបានចូលប្រឡងបាលីនៅក្រុងបាងកកជាប់បានទីជាមហា, មានកិត្តិស័ព្ទល្បីល្បាញថា ជាអ្នកប្រាជ្ញយ៉ាងជំនាញមួយរូប ក្នុងរជ្យព្រះបាទអង្គអេង, ព្រះបាទអង្គច័ន្ទ និងព្រះបាទអង្គឌួង ។ ដំបូងលោកបានជាចៅអធិការវត្តចតុរទិស នៅក្រុងឧដុង្គ និងបានទទួលសមណស័ក្តិជាទី មហាព្រហ្មមុនី បានជាគ្រូព្រះរាជបុត្រនៃព្រះបាទសម្តេចព្រះនារាយណ៍រាមាធិបតី (ព្រះអង្គអេង) ទាំង៤ព្រះអង្គគឺ: ព្រះអង្គចន្ទ, ព្រះអង្គស្ងួន, ព្រះអង្គអឹម និងព្រះអង្គឌួង ហើយជាឧបជ្ឈាយ៍បំបួសព្រះអង្គឌួងជាសាមណេរផង ។

កាលឆ្នាំវកចត្វាស័ក ពុទ្ធសករាជ ២៣៥៥ ព្រះអង្គអឹមទីជាសម្តេចព្រះស្រីជ័យជេដ្ឋាមហាឧបរាជ និងព្រះអង្គឌួង ស្តេចទៅក្រុងបាងកក, ព្រះមហាព្រហ្មមុនី ងង ក៏បានតាមហែស្តេចទៅផង ។

ចំណេរកាលមក ព្រះអង្គដួងស្តេចត្រឡប់មកព្រះនគរវិញ ទ្រង់គង់នៅស្រុកមង្គលបុរី ខែត្របាត់ដំបង ព្រះមហាព្រហ្មមុនី នង ក៏ត្រឡប់មកវិញដែរ នៅជាមួយព្រះអង្គដួង ហើយលាចាកសិក្ខាបទ មានភរិយានៅទីនោះ ។ ភរិយាដំបូង ឈ្មោះនាងមាស ។

បន្ទាប់មក ព្រះករុណាព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី (ព្រះអង្គដួង) កាលមុនសោយរាជ្យ ទ្រង់បានព្រះរាជទានអ្នកម្នាង១ នាក់ ឈ្មោះ គួច ឲ្យជាភរិយាទៀត ។ លោកមានបុត្រធីតា៩នាក់ ដែលកើតអំពីភរិយាទាំងពីរនេះ គឺខាងនាង មាស ៦ នាក់ (ប្រុស២ស្រី៤) ។ នាង គួច ៣ នាក់ (ប្រុស២ ស្រី១) ។ ខាងនាង គួច ស្លាប់កូនប្រុស១។

កូនប្រុស ៗ សុទ្ធតែបានធ្វើជាមន្ត្រីធំ ៗ ទាំងអស់ ។ ឯកូនស្រី ៗ ក៏បានជាភរិយានៃនាម៉ឺនមុខមន្ត្រី ក្នុងជំនាន់នោះទាំងអស់ដែរ ។ តំណនៃកូនចៅឧកញ៉ាព្រះឃ្លាំង នង នេះ យើងបានស្រាវជ្រាវរកឃើញខ្លះដែរ, តែមិនបាននាំយកមកតពណ៌នាក្នុងទីនេះទេ ។

ក្រោយនោះ ព្រះអង្គដួង បានប្រាប្តាភិសេក ប្រាកដព្រះនាមាភិធេយ្យ ជាព្រះបាទសម្តេចព្រះហរិរក្សរាមាឥស្សរាធិបតី សោយរាជសម្បត្តិនៅក្រុងឧដុង្គមានជ័យហើយ ទ្រង់ព្រះមេត្តាប្រោសយកបណ្ឌិត



មហាព្រហ្មមុនី នង មកតាំងជាព្រះអាចារ្យហ្លួង តំណែងចាងហ្វាងក្រុមរាជបណ្ឌិត និងទ្រង់ព្រះរាជទានស្រុកកោះសុទិន ឲ្យជាស្រុកស្ងួយរបស់លោក ដរាបដល់អាយុ ។

ឧកញ៉ាព្រះឃ្លាំង នង ជាប្អូនបង្កើតរបស់មាតានៃព្រះបរមជាតិក្សត្រី គឺសម្តេចព្រះវររាជជននីបរមបពិត្រ ដ៏ជាព្រះជននីនាថ នៃព្រះបាទសម្តេចព្រះនរោត្តម ។

លោកជារាជបណ្ឌិតមានឋានន្តរស័ក្តិ ៣ ថ្នាក់គឺឧកញ៉ាវង្សាសពេជ្ឈ, ឧកញ៉ាវង្សាក្សត្រី, ឧកញ៉ាព្រះឃ្លាំង ។ លោកបានតែងរៀបរៀងសុភាសិតជំបូន្មាន និងសាស្ត្រាផ្សេង ៗ ជាច្រើន, តែដែលយើងបានស្រាវជ្រាវរកឃើញក្នុងពេលនេះ គឺ:

— ច្បាប់សុភាសិត ពាក្យកាព្យ (ម.ស. ១៧១២—គ.ស. ១៧៩០ ក្នុងគ្រាជាឧកញ៉ាវង្សាសពេជ្ឈ- រាជ្យព្រះបាទអង្គអេង) ។

— លោកនយប្បករណ៍ ពាក្យកាព្យ (ម.ស. ១៧១៧ - គ.ស. ១៧៩៤ ក្នុងគ្រាជាឧកញ៉ាវង្សាក្សត្រី-រាជ្យព្រះបាទអង្គអេង) ។

— បុញ្ញសារសោរសោ ពាក្យកាព្យ (ម.ស. ១៧១៩-គ.ស.១៧៩៧

ក្នុងងារជាឧកញ៉ាវង្សាក្សត្រ-រាជ្យព្រះបាទអង្គអេង(១) ។

– ភោគកុលកុមារ ពាក្យកាព្យ (ម.ស. ១៧២៦-គ.ស. ១៨០៤ ក្នុងងារជាឧកញ៉ាព្រះឃ្លាំង–រាជ្យព្រះបាទអង្គច័ន្ទទី ២ ) ។

(ដកស្រង់ពីឯកសាររបស់លោកឧកញ៉ា ទេពពិទូ ឈឹម-ក្រសែម អតីតអ្នកនិពន្ធនៅពុទ្ធសាសនបណ្ឌិត្យ និងឯកសាររបស់លោក ថាប – ពិន អធិបតីនៃក្រុមជំនុំទំនៀមទំលាប់ខ្មែរ នៅពុទ្ធសាសនបណ្ឌិត្យ ) ។

---

១—ទស្សនាវដ្ដី វិទ្យាស្ថានជាតិគរុកោសល្យលេខ ២ ឧសភា ១៩៥៩ ថា សាស្ត្រាបុញ្ញាសារស័រសោ និពន្ធក្នុងគ.ស. ១៧៩៧ រាជ្យព្រះអង្គអេង ។ តែបើតាម កម្ពុជាវិតារដែលថា រាជ្យព្រះអង្គចន្ទពី គ.ស. ១៧៩៦ ដល់ ១៨៣៤ នោះ គួរជានិពន្ធក្នុងរាជ្យព្រះអង្គចន្ទវិញ? ។

ពុទ្ធសាសនបណ្ឌិត្យ

# សង្ខេបរឿងភោគកុលកុមារ

កាលព្រះសម្ពុទ្ធគង់នៅវត្តព្រះជេតពនក្រុងសាវត្ថី, ភិក្ខុទាំងឡាយ បានប្រជុំគ្នាក្នុងធម្មសភា និយាយពីរឿងភិក្ខុទេវទត្តដែលព្យាយាមពិឃាតព្រះពុទ្ធជាម្ចាស់ តែមិនបានសម្រេចដូចបំណង ក៏បែរជាទទួលគ្រោះថ្នាក់ខ្លួនឯងទៅវិញ ដោយត្រូវព្រះធរណីស្រូបទាំងរស់ ទៅកើតក្នុងមហានរកអវិចី ។ ព្រះសាស្ដាយាងមកកាន់ទីប្រជុំនោះ ទ្រង់ត្រាស់សួរពួកភិក្ខុថា "ប្រជុំគ្នានិយាយពីរឿងអ្វី?" ។ ពួកភិក្ខុក្រាបទូលថា "ប្រជុំនិយាយពីរឿងទេវទត្តព្យាយាមពិឃាតព្រះអង្គ" ។ ព្រះអង្គត្រាស់ថា "ទេវទត្តព្យាបាទសម្លាប់ព្រះអង្គ ហើយវិនាសខ្លួនឯង មិនតែក្នុងបច្ចុប្បន្នជាតិនេះទេ ពីបុព្វជាតិមក ក៏ដូច្នេះដែរ" ។ ភិក្ខុទាំងនោះបានសូមអារាធនាព្រះអង្គឲ្យសំដែងពីរឿងនេះ ទើបទ្រង់ដើមនាំអតីតនិទាន ដូចយើងបង្រួញដោយសង្ខេបតទៅនេះ ។

ក្នុងអតីតកាល, គ្រាដែលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងក្រុងពារាណសី, កាលនោះ មានមហាសេដ្ឋីម្នាក់ឈ្មោះភោគវឌ្ឍី មានទ្រព្យសម្បត្តិច្រើនដល់ទៅ ១៨ កោដិឃ្លាំង ព្រមទាំងមានសន្តានចិត្ត

សប្បុរស បានបរិច្ចាគធនធានធ្វើបុណ្យឲ្យទាន ទាល់តែអស់ទ្រព្យសម្បត្តិ ធ្លាក់ខ្លួនទៅជាអ្នកកំសត់ទុគ៌ត ។ គាត់មានកូនប្រុសតែមួយសន្មតនាមថា គោតវិល្ល ស្របគ្នានឹងនាមរបស់គាត់ជាឪពុកដែរ ។ សេដ្ឋីជាបិតាបាន ទទួលមរណកាលទៅដោយពេកចាស់ជរា បានទៅកើតជាព្រះឥន្ទ្រាធិ-រាជ១អង្គថា គោតវិល្លជាកូនរបស់ខ្លួនមានសេចក្តីលំបាកតោកយ៉ាកតែពីរ នាក់ប្តីប្រពន្ធ ក៏បានសុំអញ្ជើញព្រះបរមពោធិសត្វ ដែលឋិតនៅស្ថាន ត្រៃត្រិង្សឲ្យចុះមកចាប់បដិសន្ធិក្នុងផ្ទៃភរិយារបស់គោតវិល្ល ហើយបានសុំ អញ្ជើញនាងទេពធីតាម្នាក់ទៀត ឲ្យចុះមកកើតជាព្រះរាជបុត្រី ព្រះបាទ សត្តកុដរាជ នៅសត្តកុដបុរី ដើម្បីឲ្យបានជាភរិយារបស់ព្រះពោធិសត្វ ។ កាលព្រះពោធិសត្វប្រសូតមក មាតាបិតាបានដាក់នាមថា គោតកុល-កុមារ ។ លុះគោតកុលកុមារ មានអាយុ ១០ ឆ្នាំ មាតាទទួលអនិច្ចកម្ម ទៅ ដល់អាយុ ១៥ ឆ្នាំ គោតវិល្ល ជាបិតា ទទួលមរណកាលទៅ ទៀត នៅកំព្រាតែម្នាក់ឯង ។ គោតកុលកុមារ ប្រកបរបរធ្វើចំការ នៅទួលព្រៃមួយ ដោយព្រះឥន្ទជាជីតា បានជួយជ្រោមជ្រែងនិម្មិត ធ្វើឲ្យព្រៃនោះឲ្យស្អាតបាតល្អស្មើជាដំបូង ។ កុមារនេះ បានសុំកូនឆ្កែស មួយពីជួនចាស់ម្នាក់គ្រាន់បានជាគ្នា ។ ជួនចាស់នោះបានសុំគោតកុល-



កុមារធ្វើជាកូនធម៌ ។ គ្រានោះ ព្រះឥន្ទ្រាធិរាជបានទៅសុំព្រះរាជធីតា នៃព្រះបាទសត្តកុដរាជ យកទៅផ្សំផ្គុំជាភរិយារបស់គោតកុលកុមារ ។ ក្នុងការបំពេញករណីយកិច្ចនេះ, ព្រះឥន្ទបានបំពេរយកនាងទៅដាក់ក្នុង ចំការនៃគោតកុលកុមារព្រមទាំងបាននិម្មិតថង់ស្បែកមួយ ឲ្យនាងចូលពួន ក្នុងថង់នោះហើយប្រាប់ថា បើនាងត្រូវការវត្ថុ នាងអាចលូកយកក្នុងថង់ នេះបានទាំងអស់ តាមបំណង ។ គោតកុលកុមារ បានដឹងដោយសារ សុនខរបស់ខ្លួនប្រុសជាដំបូង ទើបទៅរើសថង់នោះ យកមកទុកក្បែរ ដំណេកក្នុងខ្ទម ។ ព្រឹកឡើងកុមារចេញទៅដំរះស្មៅចំការបាត់ទៅ នាង កញ្ញាចេញពីក្នុងថង់មកក្រៅ បោសច្រាសសំអាតទីលំនៅ រៀបចំអិន ភោជនាហារ ទុកឲ្យគោតកុលកុមារសព្វគ្រប់ហើយ ក៏ចូលទៅពួនក្នុងថង់ នោះវិញទៅ ។ កុមារកំសត់ ត្រឡប់មកពីចំការវិញ បានឃើញចំណី អាហាររៀបចំស្រេចស្រាប់ ក៏ចរិះគិតដោយសេចក្តីរីករាយនិងដោយការ មន្ទិលសង្ស័យផង ។ នាងកញ្ញាតែងធ្វើរបៀបនេះរៀងរាល់ថ្ងៃ ។ ថ្ងៃ ក្រោយ គោតកុលកុមារ ធ្វើឧបាយកលជាទៅធ្វើចំការហើយវិលត្រឡប់ មកពួនលបចាំមើល បានឃើញនាងក៏សាកសួរអំពីប្រវត្តិហេតុរបស់នាង។ និយាយប្រាប់សព្វគ្រប់តាមដំណើរ ។ អ្នកទាំងពីរបានគ្នាជាភរិយាស្វាមី

តាំងពីពេលនោះតទៅ ៗ ភោគកុលកុមារ បានសន្មតនាមនាងជា សុខុមាលន្ទាទេវី ៗ

ថ្ងៃក្រោយមក, គាមភោជក (មេស្រុក) បានឃើញកិរិយារបស់ ភោគកុលកុមារមានរូបស្រស់ប្រិមប្រិយ, ស្រឡាញ់ចង់បាននាងមកធ្វើជា ប្រពន្ធខ្លួន តែឃើញថានាងមានឋានៈខ្ពស់ មិនងាយនឹងស្រឡាញ់នាង បាន ក៏ចូលទៅក្រាបបង្គំទូលព្រះបាទព្រហ្មទត្ត ធានាក៏បរងថានឹងរក មធ្យោបាយយកនាងមកថ្វាយជាអគ្គមហេសីទាល់តែបាន, ព្រះបាទព្រហ្ម- ទត្តមានព្រះរាជហឫទ័យស្របតាមដោយសេចក្តីរីករាយ រួចហើយទ្រង់ បានធ្វើឧបាយកលផ្សេង ៗ តាមការណែនាំនៃគាមភោជក គឺទ្រង់ត្រាស់ បង្គាប់ឲ្យភោគកុលកុមាររកមាន់មកប្រជល់នឹងមាន់ព្រះអង្គ- ឲ្យរកដំរីមក ប្រជល់នឹងដំរីព្រះអង្គ- ឲ្យលួកទឹកក្តៅក្នុងខ្ទះ ដោយដាក់កំរិតថា បើភោគ- កុលកុមារចាញ់ត្រូវថ្វាយនាងសុខុមាលន្ទាទៅជាអគ្គមហេសី ៗ ភោគកុល- កុមារមានជ័យជំនះជាដរាប ដោយសារឧបាយកលរបស់នាងផងកិរិយា ដែលបានធ្វើតាមបណ្តាំព្រះឥន្ទ្រ ៗ ព្រះរាជាទ្រង់កើតទុក្ខទោមនស្សជាខ្លាំង អស់សង្ឃឹមក្នុងរឿងនេះ, ទើបរិះរកឧបាយកលមួយផ្សេងទៀត ដើម្បី បំផ្លិចបំផ្លាញនាងឲ្យព្រាត់ប្រាសពីភោគកុលកុមារទៅវិញ គឺការបង្កិតបន្ទំ



ឲ្យភោគកុលកុមារ ចរភោគចំណីអាហារ លាយដោយស៊ុតមាន់ទា ដែលត្រូវតម រហូតទាល់តែនាងសុខុមាលន្ទា កើតសេចក្តីក្តៅក្រហាយ រត់ត្រឡប់ទៅនគរនាងវិញបាត់ទៅ ៗ

ឯភោគកុលកុមារ,ធ្វើដំណើរដោយលំបាកច្រើនថ្នាក់ទៅតាមរកនាង សុខុមាលន្ទា រហូតដល់សត្តកុដបុរី ក៏បានទទួលរាជាភិសេកគ្រប់គ្រងរាជ- សម្បត្តិនៅនគរនោះ ប្រកបដោយសិរីសួស្តីជ័យមង្គលដ៏អស្ចារ្យ ៗ កាល បានរាជាភិសេករួចហើយ, ព្រះពោធិសត្វ (ភោគកុលកុមារ) និងព្រះអគ្គ- មហេសី ក្រាបថ្វាយបង្គំលាព្រះវរមាតាបិតាវិលត្រឡប់ទៅនគរពារាណ- សីវិញ ដើម្បីចង់ដឹងឧបាយកលរបស់គាមភោជកនិងព្រះបាទព្រហ្មទត្ត តើនឹងធ្វើដូចម្តេចទៀត ៗ ក្នុងដំណើរទៅនេះ, ព្រះពោធិសត្វសុំយកតែ សេះអាជានេយ្យ ១ និងធ្នូជ័យ ១ ៗ ទ្រង់បានទៅដល់ទីចំការ ក៏ធ្វើ ហាក់មិនដឹងមិនឮរឿងអធិករណ៍អ្វីទាំងអស់ គឺទ្រង់ទៅនៅក្នុងខ្ទមនោះ ដូចធម្មតារៀងមក ៗ ដំណឹងនេះ លេចឮដល់គាមភោជក ៗ ទៅ ទូលញុះញង់ព្រះបាទព្រហ្មទត្តថា ភោគកុលកុមារ មានចិត្តក្បត់ចង់ច្បាំង ដណ្តើមយកនគរពារាណសី ៗ ព្រះបាទព្រហ្មទត្ត លើកទ័ពទៅឡោម ព័ទ្ធព្រះពោធិសត្វ ៗ យឹតធ្នូថ្ងៃសរព្រួស រកក្រើករំពើកអស់ទាំងព្រះធរណី ៗ

ស្តេចជាបច្ចាមិត្តទាំងតាមគោដកស្តុករន្ធត្ជាក់ពីលើខ្នងដំរី ក្សិណក្ស័យជីវិតក្នុងគ្រានោះទៅ ។ ពួកមន្ត្រីនិងសេនាយោធា ក៏បានចុះចូលមូលមកសុំអញ្ជើញព្រះពោធិសត្វឲ្យសោយរាជ្យក្នុងក្រុងនគរពារាណសី ។ កាលបានទទួលរាជ្យរួចហើយ ព្រះពោធិសត្វព្រមទាំងព្រះអគ្គមហេសី ស្តេចយាងត្រឡប់ទៅនគរសេត្តកុដវិញតាមផ្លូវទឹក ដើម្បីសួរសុខទុក្ខព្រះវរមាតាបិតា ។ គង់នៅទីនោះបាន ៣ ខែ ក្សត្រទាំងពីរអង្គ ក៏ថ្វាយបង្គំលាព្រះវរមាតាបិតា វិលត្រឡប់ទៅក្រុងពារាណសីវិញទៀត ដើម្បីគ្រប់គ្រងរាជ្យនៅទីនោះជាស្ថាពរតទៅ ។ គ្រានោះ ព្រះបាទសេត្តកុដរាជ ទ្រង់បានប្រទានព្រះរាជដំបូន្មានក្រើនរំលឹកព្រះពោធិសត្វ ឲ្យប្រព្រឹត្តតាមទសពិធរាជធម៌កុំបីឃ្លៀងឃ្លាត ។ ឯព្រះវរមាតា ក៏បានទូន្មានព្រះរាជបុត្រីឲ្យប្រព្រឹត្តប្រតិបត្តិតាមក្រិត្យក្រមរបស់ស្ត្រីដែរ ។ ព្រះបាទភោគកុលនិងព្រះអគ្គមហេសី ទ្រង់សោយរាជសម្បត្តិក្នុងក្រុងពារាណសី ប្រកបដោយទសពិធរាជធម៌ ព្រមទាំងទ្រង់ប្រទានដំបូន្មានខាងផ្លូវលោកនិងផ្លូវធម៌ច្រើនបែបច្រើនបទ ដល់ប្រជារាស្ត្រឲ្យបានសេចក្តីសុខចម្រើនសម្បូរសប្បាយ ដរាបដល់ទ្រង់ចាស់ជរា សោយព្រះទិវង្គតទៅ ទ្រង់បានទៅសោយសម្បត្តិសួគ៌ានស្ថានតុសិតទាំងពីរព្រះអង្គ ។

# រឿងភោគកុលកុមារ

## បទកាកគតិ

១– អហំ នមោ នមក្ការេ អញ្ជលិំ សុសិរសា
ពុទ្ធសេដ្ឋំ លោកុត្តមំ តមោនុទោ ។ នមធម្មំ
សុខាវហំ អរិយបថោ ទេវជនំ មោក្ខមគ្គោ សន្តិ-
ការេ និយ្យានិកំ ។ នមសង្ឃ វរិសុទ្ធោ ទក្ខិ-
ណេយ្យំ សន្តិន្ទ្រិយំ បុញ្ញក្ខេត្តំ អនាសវំ សមិទ្ធិយោ ។

អហំ ខ្ញុំ    នមោ បង្គំ    នមក្ការេ
ក្រញាក្រាបនមស្ការ    ពុទ្ធសេដ្ឋ(១)    អញ្ជលិយោ
លើកអញ្ជលី ។

៤– សុសិរសា    ផ្គុំហត្ថា    ដាក់ដល់សិរសី
ពុទ្ធសេដ្ឋ    វន្ទាព្រះស្រី    សារពេជ្ជមុនី
ប្រសើរសួស្តីសម ។
តមោនុទោ(២)    លោកុត្តមោ(៣)    ព្រះអង្គឧត្តម

---

១ ព្រះពុទ្ធដ៏ប្រសើរបំផុត ។ ២ កំចាត់នូវងងឹតគឺអវិជ្ជា ។ ៣- ប្រសើរបំផុតក្នុងលោក ។

លើសលែងមនុស្ស ទេវតាឥន្ទ្រព្រហ្ម បន្ទាបង់បំ-

បាត់បាបវេរ ៗ

នមធម្មំ(១) សុខាវហំ(២) អញខ្ញុំវន្ទា

បង្គំព្រះធម៌ សុពណ៌កេត្រា(៣) នាំសត្វសុខសា-

ប្បាយបាននិព្វាន ៗ

អរិយបថោ(៤) ទេវជនោ(៥) ជាមាគ៌ាឋាន

សព្វសត្វមនុស្ស ទេវតាឲ្យបាន យង់យល់ត្រើយត្រាណ

អមតបុរី ៗ

មោក្ខមគ្គោ(៦) សន្តិករោ(៧) នាំសត្វគពត្រើ

ដាក់ដល់ឋិតឋាន និព្វានជាទី ពឹងពាក់ពួនពី

ក្ដិកពាតណ្ហា ៗ

១០– នមសង្ឃ(៨) វរវិសុទ្ធោ(៩) អញខ្ញុំវន្ទា

បង្គំព្រះសង្ឃ ទ្រទ្រង់វគ្គា សីលសុទ្ធសេដ្ឋា

---

១– សូមនមស្ការដល់ព្រះធម៌។ ២– នាំមកនូវសេចក្ដីសុខ។ ៣–សំពៅមាស។ ៤–ជាផ្លូវគន្លងព្រះអរិយបុគ្គល ។ ៥– ទេវតានិងមនុស្ស ។ ៦–ជាផ្លូវនៃព្រះនិព្វាន ។ ៧– ជាធម៌ធ្វើនូវសេចក្ដីស្ងប់ ។ ៨–សូមនមស្ការដល់ព្រះសង្ឃ។ ៩–បរិសុទ្ធប្រសើរដោយវិសេស។



ប្រសើរពេកពន់ ៗ

សន្តិន្ទ្រិយំ(១) បុញ្ញក្ខេត្តំ(២) អស់អង្គអរហន្ត

សង្រួមកាយា មេត្តាលើសលន់ ជាតិជាស្រែបុណ្យ

សព្វសត្វសម្លាយ ៗ

អនាសវោ(៣) សមិទ្ធិយោ(៤) សុខសួស្ដីពណ្ណរាយ

ឥតបាំនលំនៅ ឥតក្ដៅក្រហាយ ឥតអន្តរាយ

ដូចក្ដីប្រាថ្នា ៗ

មហាសករាជកប់ បួលជាឯកស័ក្ត- ពោធសកា

ចួបចូលវស្សាន(៥) សាវ័ណមាសា(៦) កុម្ភពារ(៧)

បុណ្ណមិយំ(៨) ៗ

នាមោមយា នងនាមជាតិជា ខុកញ្ញាព្រះឃ្លាំង

គន់គិតកាព្យកិច្ច ពាក្យពេចន៍ទុកតាំង ជាគ្រឿងតំណាំង

តំណសាសនា ៗ

---

១–មានឥន្ទ្រិយដ៏ស្រគត់ស្រគំ ។ ២–ជាស្រែបុណ្យ ។ ៣–មិនមានអាសវក្កិលេស ។ ៤–មានរិទ្ធិអំណាចច្រើន ។ ៥– រដូវខែភ្លៀង ។ ៦–ខែស្រាពណ៍ ។ ៧– ថ្ងៃអង្គារ ។ ៨– ក្នុងថ្ងៃពេញបូណ៌មីគឺ ១៥ កើត ។

១៩— កប្បកាលពោធិ· សត្វសាងបារមី ក្នុងសង្សារ
អន្ទោលទៅមក យោនយកជាតិជា ភោគកុលកុមារ
ទុគ៌តពេកពន់ ។
បានជាមហា- ក្សត្រគ្រេមចិន្តា បរិបូណ៌បទបុណ្យ
ដ្បិតផលសំណាង ស្ដេចសាងច្រើនលន់ ទើបខ្ញុំគិតគន់
ចងជាកាព្យទុក ។
គុណសាសនា ប្រាំពាន់វស្សា ជាផលទៅមុខ
សូមសំរេច សិរីសួស្ដីសុខ បៀសវាកពោសទុក្ខ
ភ័យផងសម្ងាយ ។
សូមលុះគន្ធង នៃអ្នកប្រាជ្ញផង ពីបូរាណនាយ
សូមតានពុទ្ធបាទ សព្វជាតិជិតឆ្ងាយ សូមទេពតាំងឡាយ
ជួយជ័យបេស្កា ។
ខ្ញុំសូមជំណើរ ដំណាលសរសើរ កាលព្រះភគវ(១)
សារពេជពុទ្ធពង្ស ស្ដេចគង់ធម្មា អាស្រ័យនៅនា
វត្តព្រះជេតពន ។

---
១ ព្រះដ៏មានព្រះបុណ្យ ។



២០— ព្រះអង្គមេត្តា នាំធម៌ទេសនា ប្រោសប្រាប់មហាជន
ភិក្ខុសុសង្ឃ(១) អស់អង្គអរហន្ត បានបរិបូណ៌បុណ្យ
ដោយពុទ្ធវចនា ។
មានកាលមួយថ្ងៃ ភិក្ខុផងច្រើនក្រៃ ជួបជុំចរចា
ពីព្រះទេវទត្ត កាចគិតប្រាថ្នា បៀតបៀនពាធា
ចិត្តចង់ពិឃាត ។
នៃព្រះសម្មា- សម្ពុទ្ធសាស្ដា- ចារ្យបមលោកនាថ(២)
គាត់គិតកលជ្ញើ អំពើប្រមាថ ប៉ុនប៉ងពិឃាត
ព្រះអង្គពុំបាន ។
ឯអង្គទេវទត្ត បាបតាមទាន់គ្នាត់ ពេកពន់ប្រមាណ
ព្រះធរណីស្រូប ទាំងរូបទៅបាន កើតជាប្រេតប្រាណ
នៅនាអវិចី ។
កាលនោះសម្ដេច ព្រះស្រីសារពេជ ប្រាបសព្វសេចក្ដី
ដោយចិត្តស្រោតស្រេច(៣) ទើបស្ដេចចេញពី សុគន្ធកុដី(៤)

---
១- ភិក្ខុសង្ឃដ៏ទ្រង់សីលល្អបរិសុទ្ធ ។ ២- បមលោកនាថ គឺជាកំពូលទីពឹងរបស់សត្វលោក ។ ៣- ត្រជៀកចិត្ត ។ ៤- កុដិដែលមានក្លិនក្រអូប ។

សយនោត្តម(១) ៗ

២៩– ព្រះអង្គចរចាក　ឆ្ពោះជម្ពូសាគរ　សាលាជំនុំ
ថែរបើកព្រះសូរ　មធុរសូរស្តីសំ(២)-　ឡេងឮដូចព្រហ្ម
បន្ទូលទៅថ្កាន ៗ
ថាហៃអាវុសោ　នៅថ្ងៃនោ ៗ　មិនទៅស្មានមាន(៣)
បម្រើនមេត្តា　ភាវនានាំប្រាណ　ឲ្យបរិបូណ៌បាន
ដូចក្តីប្រាថ្នា ៗ
ទើបអស់ភិក្ខុផង　ប្រណម្យសាសង　ទូលព្រះពុទ្ធដីកា
អស់យើងខ្ញុំ　មកជុំជួបគ្នា　និយាយអនិច្ចា
ពីព្រះទេវទត្ត ៗ
កាចគិតប្រមាថ　ចិត្តចង់ពិឃាត　បៀតបៀនបំបាត់
ព្រះជន្មព្រះអង្គ　ពូជពង្សពុទ្ធរតន៍　ពុំបានដូចចិត្ត
ដូចក្តីប្រាថ្នា ៗ

---

១ ជាក្រឡាព្រះបន្ទំដ៏ឧត្តម ។ ២-មធុរៈ ពីរោះផ្អែមល្ហែមឆ្ងាញ់ពីសា ។ មានបញ្ចប់ខ្វះជា មធុរភិរម្យ សំឡេងឮពព្រហ្ម ដូច្នេះក៏មាន ។ ៣-ឬបច្ចុះជា ស្មាធិជ្យាន ។



ប្រែជាប្រាសប្រាណ　អង្គអន្តរធាន　បាត់បង់កាត្វា
បាបតាមទាន់ហាន់　ទុរន់ទុក　ទល់ទុក្ខវេទនា
លំបាកពេកក្តាត់ ៗ

៣០– សម្តេចភគវ　មានព្រះពុទ្ធដីកា　ព្រះសូរសារស័ព្ទ
ថាហៃភិក្ខុសង្ឃ　ឯអង្គទេវទត្ត　ចង់ពៀរចាំចិត្ត
ប៉ុនប៉ង់ពិឃាត ៗ
ធ្វើអង្គតថា-　គតតែមិនគ្រា　បច្ចុប្បន្នជាតិ
ពុំបានដូចចិត្ត　កាចគិតប្រមាថ　មានពីបុព្វជាតិ
មុនមកច្រើនគ្រា ៗ
បន្ទូលតែម៉្លោះ　បញ្ឈប់នៅនោះ　ពុំមានពុទ្ធដីកា
អស់ភិក្ខុទាំងឡាយ　ក្រាបថ្វាយវន្ទា　សូមអារាធនា
ព្រះធម៌ថ្វាថៃ ៗ

កាលនោះព្រះអង្គ សារពេជ្ញស្តេចទ្រង់ ព្រះទិព្វញាណញេយ្យ(១)
ស្តេចបើកព្រះសូរ　មធុរប្រពៃ　ត្រេកត្រាស់ថាហៃ
អាវុសោបរិស័ទ ៗ

---

១-ព្រះប្រាជ្ញាញាណដ៏ជាទិព្វ ព្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ។

កាលកប្បខ័ណ្ឌទាំង ស្ងាត់បាត់កំបាំង កន្ទងលង់ភ្លាត់
មានក្សត្រនាមនាថ ព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិ
ពារាណសី ។

៣៩- កាលនោះមានមហា សេដ្ឋីនាមា ឈ្មោះគោតវង្ស
និត្យនៅគាមា(១) មួយនាខាងទី ទិសបូព៌បុរី
បុកណារដ្ឋ(២) ។

ឯអគ្គសេដ្ឋី នោះកាលអំពី មុនមានទាសា
ទាសីទ្រព្យធន ច្រើនលន់មហិមា ប្រមាណអដ្ឋា-
សេកោដិ(៣)ឃ្លាំងនោះ ។

សេដ្ឋីធ្វើបុណ្យ ឲ្យទានទ្រព្យធន សព្វថ្ងៃចំពោះ
ទុទ្ទិសជាផល តំកល់ចិត្តស្មោះ ទ្រព្យផងរលស់
ពីឃ្លាំងអស់ទៅ ។

ធ្វើបុណ្យឲ្យទាន ទ្រព្យគង់ប្រមាណ រវេះមួយនៅ
អស់ខ្ញុំទាំងឡាយ ខ្ចាត់ខ្ចាយបាត់ទៅ សេដ្ឋីនោះនៅ

១ ស្រុក, ភូមិ ដំបន់ ។ ២ ដែនបុកណា, ខេត្រដែនចាស់ ។ ៣ អដ្ឋារសៈ ១៨ គឺ១៨ កោដិឃ្លាំង ។



តែនឹងភរិយា ។

បង្កើតមានបុត្រ ប្រុសមួយសន្ធត នាមឈ្មោះហៅថា
ហៅគោតវង្ស ដូចចិត្តបិតា ចម្រើនជន្មា
បានឆ្នាំខែ ។

៤០- សេដ្ឋីបិតា ចាស់ជាតិជរា បៀបបៀនក្សិណក្ស័យ
ហេតុផលឲ្យទាន ធនធានច្រើនក្រៃ មិនមានសង្ស័យ
ធុញថប់បារម្ភ ។

ទើបទៅកើតជា សម្ដេចឥន្ទ្រា- ធិរាជឧត្តម
ឋិតត្រៃត្រឹង្ស សួគ៌ាសោយស- ម្បត្តិបានជាធំ
លើសលែងទេវតា ។

ទៀនទើបព្រះអង្គ ព្រះឥន្ទ្រស្ដេចទ្រង់ បើកទិព្វចក្ខុ
មើលមកយល់បុត្រ ទុគ៌តកំព្រា តែនឹងភរិយា
ក្សិណក្សត់ធនធាន ។

សម្ដេចព្រះឥ- ន្ទ្រាទ្រង់ព្រះចិ- ន្តាដោយព្រះញាណ
ជាចេះគួរអញ ប្រោសប្រាណឲ្យបាន កូនប្រុសឲ្យមាន
ត្រកូលតទៅ ។

កាលនោះព្រះពោ- ធិសត្វសោផ្លា វិសេសឋមពៅ
កើតជាទេវបុត្រ បរិសុទ្ធឋិតនៅ ពិមានមាសផ្អៅ
នៅត្រៃត្រឹង្ស ។

៤៥- ទើបព្រះឥន្ទ្រទៅ ដល់ឋានលំនៅ ពន្លកសាស្តា
ទូនអង្គអភិវាទ អារាធនា អញ្ជើញព្រះមហា-
បរមពោធិ ។

ឲ្យស្តេចចាកឋាន សួគ៌សុខពិមាន យោនយកប្រដិ-
សន្ធិក្នុងទរ បវរមហេសី នៃគោត្រវង្ស
ជាបុត្រអាត្មា ។

ហើយព្រះគោសិយ អញ្ជើញនាងស្រី វត្តទេពធីតា
ឲ្យចុះចាកឋាន ពិមានសួគ៌ា ឲ្យបានជួបជា
គូនឹងពោធិ ។

ពង្សព្រុទ្ធពន្ធុក ស្តេចទទួលយក និមន្តគោសិយ
ស្តេចចង់សន្សំ បន្ទុំបារមី នាំសត្វពួនពី
ភ័យភពតណ្ហា ។



៤៩- ស្រេចស្តេចវិមុត្ត[១] ជាតិច្យុត ចាកត្រៃត្រឹង្ស
ចាប់យកប្រដិ- សន្ធិនៅនា ឧទរកែវយោ
នៃគោត្រវង្ស ។

## បទព្រហ្មគីតិ

នាក្នុងរាត្រីកាល នោះនាងនាថវរទេវី
ករិយាគោត្រវង្ស យង់យល់សប្តបូពនិមិត្ត ។
យល់ដូចដើងសុវណ្ណ តម្រួតគ្នាទាំងពីរពិត
នៅនាក្នុងឋានបិត ដាក់កណ្តាលមណ្ឌលទី ។
មានដើមចម្ប៉ាផុះ ក្នុងដើងនោះល្អសោភី
លូតលាស់ស្លឹកខៀវខ្ចី លង់លុះបាន ១០ ឆ្នាំគត់[២] ។
ដើងដែលចម្ប៉ាផុះ លើដើងនោះបែកបង់បាត់
លុះលង់ទៅទៀតថ្ងាត់ យូរប្រមាណ ៩ វស្សា ។
ដើងមាសមួយវិញទៀត បែកបង់មៀតស្សូន្យសោះប្រា-

---

១- ផុតស្រឡះ ច្រើនសំដៅសេចក្តីផុតរួចស្រឡះចាកកិលេសតណ្ហា តែក្នុងទីនេះសំដៅសេចក្តីត្រឹមស្លាប់ផុតច្យុតចាកឋានសួគ៌ប៉ុណ្ណោះ ។ ២ ច្បាប់ដើមថា (១ឆ្នាំ) ប្រហែលជាបាត់០ទេដឹង ? ព្រោះសេចក្តីតទៅឃើញមានសេចក្តីបញ្ជាក់ថា១០ឆ្នាំដល់ពីរលើក ទើបកែជា(១០ឆ្នាំ) តាមសេចក្តីខាងក្រោយ ។

កដក្បូរដើមចម្ប៉ា    នោះអណ្ដែតត្រសែតទៅ ។
បិតកណ្ដាលទឹក    មានសេក្ដីសន្ដោ
ហើយធ្លាក់ចុះមកទៅ    នាកណ្ដាលទតក ។
មានមែកបែកសន្លឹក    ល្អពន្លឹកពេកមហិមា
ប្រកបទូវបុប្ផា    ពិដោរសាយសព្វទិសផង ។
នាងភ្ញាក់ឡើងប្រាយប្រាប់    ស្វាមីស្ដាប់ដោយទំនង
យល់អស្ចារ្យក្នុង    ដោយនិមិត្តមិនដែលយល់ ។
លុះព្រឹកក៏ស្រេចស្រាង    ក្សិណនោះនាងនាថនិមិល
កាន់ស្វាមួដើរដល់    ឋានអ្នកប្រាជ្ញពុជបណ្ឌិត ។
ថ្លែងដូចដំណើរយល់    សប្ដមង្គលបុព្វនិមិត្ត
ឲ្យអ្នកប្រាជ្ញគន់គិត    ទាយតាមដោយក្បួនសាស្ត្រសៃយ(១) ។
កាលនោះអ្នកប្រាជ្ញប្រាយ    ស្រដីទាយទៅថាហៃ
នាងអើយសប្ដល្អក្រៃ    នាងនឹងកើតបុត្រប្រុសប្រាណ ។
មួយមានរូបឆោមឆាយ    តាមទំនាយនិមិត្តមាន
អាយុបរិបូណ៌បាន    ដល់ ១០ ឆ្នាំពុំឃ្លៀងឃ្លាត ។

១–គម្ពីរ, ក្បួនច្បាប់ដ៏ប្រសើរវិសេស ។



អគ្គនាងជាមាតា    នឹងមរណាជីពជន្មជាតិ
ក្សិណក្ស័យឯងអគ្គកាត្ត(១)    សូន្យអសារប្រាកដក្ដាត់ ។
លុះបុត្របានគ្រាន់គ្រប់    ដល់ឆ្នាំដប់ប្រាំទៀតទាត់
បិតានឹងបង់បាត់    ជន្មជីវិតនឹងក្សិណក្ស័យ ។
បុត្រនាងនោះនឹងបាន    បុណ្យថ្កើងថ្កានជាធំក្រៃ
លើសលែងអ្នកដទៃ    ក្នុងនគរនេះជៀងជាក់ ។
កាលនោះនាងទេវី    ស្ដាប់សំដីពាក្យនៃអ្នក
ប្រាជ្ញប្រាយប្រុះប្រក្ស័ក្ស(២)    ទាយនិមិត្តសព្វសេចក្ដី ។
នាងលាអ្នកប្រាជ្ញទៅ    ឋានលំនៅមណ្ឌលទី
ប្រាយប្រាប់ព្រះស្វាមី    សព្វសេចគ្រប់ពុំភាំងភ្លាត់ ។
នាងនាថនៅរក្សា    គភ៌ព្រះមហាបុរសរ័ត្ន
លុះទំសមាសទៀតទាត់    ប្រសូតចាកព្រះឧទរ ។
បុត្ររ័ត្នរូបសោភ័ណ    ដូចសុវណ្ណថ្លៃបវរ
ទៀងទើបឲ្យនាមករណ៍    ឈ្មោះកោតកុលកុមារ ។
២០– មាតាបិតាពេញ-    ចិត្តស្រឡាញ់ថ្នមរក្សា

១–អាត្មា,ខ្លួនឯង ។ ២–ច្បាស់លាស់,ជាក់ប្រាកដ ។

ស្ងួនត្រង់បុត្រពុំង៉ា ហើយឲ្យមានភោជន៍អាហារ ។
ធ្វើបុណ្យកេក្សសីល- ប្រាំពុំខ្វិលជានិច្ចកាល
ផ្សិតផឹងដោយអាចារ្យ អ្នកប្រាជ្ញប្រាយទាយទុកថា ។
អន្តឯងនឹងក្សណក្ស័យ មរណ៍ប្រល័យជីពជន្មា
បម្រើនធមិការនោ ជានិរន្តរ៍ប្រក្រតី ។
លុះបុត្របានដល់ជប- ឆ្នាំគ្រាន់គ្រប់ទើបជននី
នាន់ក្ស័យជន្មជីវី ដូចទំនាយពុំឃ្លាតឃ្លា ។
ហេតុផលនានឲ្យមាន កាន់សីលបានបុណ្យមហិមា
ទៅកើតនៅសួគ៌ា ឋិតលើប្រាជ្ញប្រាសាទរ័ត្ន ។
ចំណោះទៅទៀតលន់ ទើបព្រះពង្សពោធិសត្វ
បម្រើនព្រះជន្មថ្វាត់ បាន១៥ព្រះវស្សា ។
ទៀនទើបអន្តសេដ្ឋី គោតវឌ្ឍីជាបិតា
មានព្យាធិពេគា ដកមកបៀតបៀនប្រាណ ។
ទុកទុរន៍សល់ កម្មមកផ្ដល់ពុំបុកណ
ហៅបុត្រត្រែកល្យាណ ទៅទៀបទើបផ្ដែផ្ដាំថា ។
ឲ្យកូនស្ងួនសំឡាញ់ អាពុកពេញចិត្តស្នេហា



ឥឡូវកម្មវេក អន្តឯងឲ្យប្រាសព្រាកព្រាត់ ។
ពុំបាននៅរក្សា បុត្រពុំង៉ាថ្លៃវ័ត្ន(១)
ចូរកូនស្ងួនស្នេហ៍ស្និទ្ធ អ្នកចាំពាក្យពីបិតា ។
ជាបើអាពុកមរណ៍ ចូរអ្នកបបួលគ្នា
មកសែងសពបិតា ទៅដាក់ដល់ព្រៃស្មសាន ។
ឲ្យអស់សត្វត្មាតក្អែក ចឹកហួរហែកផាសោះឃ្លាន
ជនទឹកដាក់ឲ្យមាន ឲ្យអស់សត្វផឹកផង ។
បើសត្វពុំស៊ីសាច់ សារសែដាច់អស់ឥន្ទ្រិយ
បាយកឆ្អឹងសិរសី មកតម្កល់ទុករក្សា ។
តាំងក្ដអាពុកនៅ បើចង់ទៅធ្វើចំការ
បាយកឆ្អឹងបិតា ចងបង្អួសទង់ទាញទៅ ។
បើឆ្អឹងអាពុកអ្នក ដាច់ជំពាក់នឹងនិត្យនៅ
ទីឋានណាចូរទៅ គិតកាប់ឈើធ្វើចំការ ។
ផ្ដាំបុត្របរិបូណ៌ស្រេច ផុតខ្យល់ដាច់ជីពជន្មា
បានទៅកើតសួគ៌ា ហេតុបុណ្យបានសាងសីលទាន ។

១– ខ្ទបកៃ ។ រូ (ក.បុ.) – ខ្ទប,ខ្ទបគា ។

គោគកុលកុមារ　យល់បិតាបាត់វិញ្ញាណ
សោយសោកសល់ប្រះប្រាណ　ពិលាបខ្ញួញទំនួញក្តាត់ ។
សង្វេគអនិច្ចា　ផ្សិតកំព្រាប្រាសព្រាត់ព្រាត់
អន្តងងួលអនាថ　អាណិតលន់ពន់ប្រមាណ ។
ស្រេចបរចេញទៅរក　មូលក្អាមកសែងសពបាន
ទៅដាក់នៅស្មសាន　តាមបណ្តាំពាក្យបិតា ។
ផងទឹកទុកឲ្យតាន　សត្វផងបានបរិភោគា
ស្រេចគោគកុលកុមារ　អ្នកយកតែឆ្អឹងសិរសី ។
វិលមកទុកតម្កល់　ក្នុងមណ្ឌលយកផ្កាភ្ញី
បូជាជាប្រក្រតី　ប្រណិប័តន៍សព្វទិវា ។

## បទកាកគតិ

រីចៅគោគកុល-　កុមារនិមិល　និត្យនៅគ្រឹហា
កណ្តាបកណ្តាង　ម្នាក់ឯងកំព្រា　មិនមានអ្នកណា
នៅជាពីរផង ។
អ្នកគិតអនិច្ចា　ខ្លួនអើយកំព្រា　ពេកពន់កន្ទង
ឥតញាតិកា　មេបារៀមច្បង　មិត្រសំឡាញ់ផង



គ្រាន់ពឹងអាស្រ័យ ។
ចេះគួរអញ្ញេក　សត្វក្អែមួយមក　ចិញ្ចឹមសព្វថ្ងៃ
ទីងផ្ញើបម្ការ　នៅនាក្នុងព្រៃ　គ្រាន់ពឹងប្រាស្រ័យ
កំដរអាត្មា ។
គិតដូច្នោះស្រេច　ពន្ទុកសារពេជ　ពូជពង្សសាស្តា
ចុះតាកមណ្ឌល　ដើរដល់គ្រឹហា　ជូនតាសមួយជា
មេមាយឥតប្តី ។
គាត់ចិញ្ចឹមក្អែ　ញីមួយជាមេ　មានកូនបានបី
មួយលឿងមួយប្រាល　ពពាលពិសី　មួយដូចសំឡី
សសុទ្ធសោភា ។
ឯចៅគោកុល-　កុមារមើលយល់　កូនសុនខា
អ្នកឡើងទៅថ្កាន　ដល់ឋានគ្រឹហា　សំពះពោលថា
បពិត្រលោកយាយ ។
ខ្ញុំនេះជា　អ្នកខ្សត់កំព្រា　ឥតឪពុកម្តាយ
ឥតញាតិផៅផង　រៀមច្បងទាំងឡាយ　តាមតែអ្នកយាយ
អាសូរករុណា ។

ខ្ញុំមកនេះមិញ ប្រាថ្នាសូមទិញ កូនសុនខា
បានមួយយកទៅ ទុកនៅជាគ្នា គ្រាន់ធ្វើបម្ការ
បញ្ចឹមជីវី ។
ជូនចាស់ស្អែនស្តាប់ អស់អាថ៌សាស័ព្ទ នៃពង្សពោធិ៍
មានចិត្តអាណិត មេត្តាប្រណី ទើបគាត់ស្រដី
ឆ្លាស់ឆ្លើយទៅថា ។
ហៃកូនកល្យាណ អ្នកនឹងចង់បាន កូនសុនខា
ម្តាយសោកព្រមឲ្យ តាមដោយចិត្តា ម្តាយពុំប្រាថ្នា
យកថ្លៃពីអ្នក ។
កញ្ញម្តាយបានជួន បានជួបអ្នកសួន ថ្លើមថ្លៃវល័គុណ៍
ល្អល្អះទោមទាយ ចិត្តម្តាយស្នោះស្ម័គ្រ ម្តាយសូមយកអ្នក
ជាកូនធម៌ថ្លៃ ។
ជូនចាស់គ្រអាល រួបរៀបអាហារ គោជន៍ក័ស្តុប្រពៃ
ឲ្យព្រះពោធិ- សត្វវិសេសថ្លៃ សោយស្កប់ស្កល់ក្រៃ
ទើបផ្តែផ្តាំថា ។
អ្នកមាសថ្លៃម្តាយ ទោះក្រទោះងាយ សុខទុក្ខមេត្តា



អ្នកកុំបោះបង់ ម្តាយលង់យូរយារ មកប្រាប់មាតា
ឲ្យដឹងសេចក្តី ។
ទើបពោធិសត្វ លើកករប្រណិប័តន៍ លាធម៌ជននី(១)
យកកូនឆ្កែស ល្អះល្អសោភ័ នាំទៅដល់ទី
លំនៅអាត្មា ។
អ្នកឲ្យបាយទឹក បរិភោគយប់ព្រឹក បញ្ចឹមរក្សា
សុនខាធំ សសមរូបា ដើរតាមកុមារ
សព្វថ្ងៃប្រក្រតី ។
លុះរដូវខែ ធ្វើចំការស្រែ ទើបព្រះពោធិ៍
យកផ្អើសិរសា បិតាចេញពី មណ្ឌលទៅទី
ព្រៃព្រឹក្សស្មសាន ។
ចង់បង្អួសទៅ ដោយផ្លូវព្រៃជ្រៅ ពីរបីថ្ងៃបាន
ពុំជាប់និត្យនៅ អួសទៅលើឋាន ទួលតូចមួយមាន
ឈើផងច្រើនប្រះ ។
ទួលនេះប្រមាណ ទំហំធំបាន ប្រាំសិនសេស្នោះ
បង្អួសទាញទៅ ដាប់ទៅឋាននោះ ដូចគេកាន់គោះ

១– ម្ដាយធម៌ ។

ដំពាក់ទិត្យនៅ ។

អ្នកក្រាបសំពះ ផ្ទឹងសិរសាព្រះ បិតាចមទៅ
ទើបអ្នកយកផ្ទឹង វិលវិញឆ្ពោះទៅ តំកល់ទុកនៅ
មណ្ឌលត្រីហា ។

លុះព្រឹកព្រាងព្រះ សូរ្យសែងរៀងរះ ពីទិសបូព៌ា
អ្នកដណ្តាំបាយ រេចស្ពាយម្ជុម្ជា ហៅសុនខា
ចរចូលក្នុងព្រៃ ។

ដល់ដែនដំពាក់ ផ្ទឹងបិតាអ្នក គិតគាប់ប្រស្រ័យ
ធ្វើជាចំការ សុំយោណ្ហាចថ្ងៃ ទើបអ្នកវិលវៃ
មកបានត្រីហា ។

កាលក្នុងរាត្រី នោះហេតុបារមី ពោធិសាស្តា
កក្រើកទៅដល់ មណ្ឌលអាសនា សម្តេចឥន្ទ្រា-
ធិរាជនិមិល ។

ព្រើសប្រែព្រះភ័ក្ត្រ បែរបើកទិព្វចក្ខុ ទៀងទតយងយល់
ពន្លកពោធិ- សត្វពិបាកសល់ ម្នាក់ឯងទុពិល
គិតគាប់បម្ការ ។



ទើបព្រះកោសិយ ចុះចាកវៃនទី សួគ៌ត្រៃត្រឹង្ស
នាំគស់បរិពារ គ្រអាលលីលា ហោះចុះមកនា
ពាកណាសី ។

ស្តេចដល់ចម្ការ បណ្តាលបេស្កា- ទុកាពបារមី
ឲ្យឈើតូចធំ រលំដល់ដី ហើយប្រាបដាច់(១)
ទួលបានចម្ការ ។

ទើបធ្វើកំណត់ សរសេរកោនកត់ អក្សរទុកថា
យើងជាព្រះឥន្ទ្រ ទេវិន្ទថ្ងៃថ្វា ជួយធ្វើចម្ការ
កោគកុលកុមារ ។

ស្រេចព្រះឥន្ទ្រា នាំអស់ទេវតា ទៅបុត្របរិពារ
វិលវិញឆ្ពោះទៅ លំនៅគគការ នៃសួគ៌ាកាល-
នោះនៃពុំលង់ ។

លុះអរុណោ- ទ័យទើបសុរិយោ រៀងរះត្រចង់
ព្រះពោធិសត្វ ប្រែក្នុពុំផ្សង ប្រជាប់ព្រះអង្គ
ហៅសុនខា ។

១· ប្រាបៈ ធ្វើឲ្យរាបស្មើ ។

អ្នកចរបេញទៅ ដល់ទីលំនៅ ព្រៃព្រឹក្សចម្ការ
យល់ឈើតូចធំ រលំលើគ្នា បាក់បែកល្អិតជា
គេកាប់ខ្ទាត់ខ្ទាយ ។

គន់គិតថៃថា អស្ចារ្យមហិមា ពេកពន់អម្បាយ
ខ្យល់ម្ដេចខ្លាំងម្លែក បោកបែកកក់កាយ ព្រៃព្រឹក្សាសាយ
រលំបែកបាក់ ។

អ្នកចរត្រេសាល ទៅដល់កណ្ដាល ចម្ការដៀនជាក់
យល់អន្តអក្សរ បវរលាយលក្ខណ៍ សរសេរជាគជាក់
ជាចារឹកថា ។

គឺអន្តសាក្រា(១) ទេវាសេដ្ឋា(២) បណ្ដាលព្រឹក្សា
ឲ្យបាក់បែកបង់ នាក្នុងចម្ការ ដៀនដួយទៅមហា
បុរសនិមល ។

អ្នកមានអំណរ សោមនស្សសាទរ ឥតងឿងឆ្ងល់
ទើបវិលវិញបាន ទីឋានមណ្ឌល អន្តឥតអំពល់
អំពីចម្ការ ។

១-សក្កទេវិន្ទ គឺព្រះឥន្ទ្រ ។ ២-ជាទេវតាដ៏ប្រសើរបំផុត ។



លង់លុះយូរថ្ងៃ ទៅទើបព្រឹក្សព្រៃ ក្រៀមស្ងួតសោះសា
អ្នកយកភ្លើងទៅ ដុតនៅចម្ការ ឆាបឆេះល្អិតជា
ពពុះផេះផង់ ។

ទើបយកពូជស្រូវ ល្អសណ្ដកទៅ ដាក់ដាំនាក្នុង
ចម្ការស្រេចស្រាប់ គិតកាប់ឈើសង់ ជាខ្ទមមួយគ្រង់
កណ្ដាលចម្ការ ។

ស្រេចទើបអ្នកយក ផ្ទាំងបាយអ្នកកេ ត្រីសាច់ម្ហូប
អំពីផ្ទះទៅ និត្យនៅក្បា ខ្ទមចាំចម្ការ
កណ្ដាលព្រៃស្ងាត់ ។

អ្នកធ្វើបេង របារចេនយន្ត ប្រយោជន៍ប្រយ័ត្ន
ការក្រែងប្រើសព្រាយ ទន្សាយសត្វសត្វ ចូលចម្ការកាត់
ដំណាំគោក្ដា ។

ឯអស់ដំណាំ ទូរស្រូវដល់ដាំ ផុះល្អមហិមា
បែកគុម្ពលូតលាស់ ហើសផ្លែផ្កា ព្រោះផ្សិតបិតា
ផ្កាទុកប្រមាន ។

មានមួយរាត្រី ការពេញបូណ៌មី អ្នកអធិដ្ឋាន

ទោះបោសចសីលសុទ្ធ ស្រគត់អស់ប្រាណ សង្រ្គមមែនមាន
ក្រិត្យក្រមវិយោ ។
រំលឹកព្រះស្រី គុណកែវទាំងបី(១) ចម្រើនភាវនា
លុះម៉ោងជួនបាន ប្រះប្រាណទិព្រា គន់គិតថប់ថា
ខអញក្រក្រៃ ។
នៅតែម្នាក់ឯង កណ្ដោចកណ្ដែន កណ្ដាលព្រឹក្សព្រៃ
មានតែផ្កស កំដរសេព្វថ្ងៃ ឥតអ្នកដទៃ
មួយមកជាគ្នា ។
ប្រសិនបើមាន ជម្ងឺក្នុងប្រាណ ព្យាធិបិណ្ឌា(២)
សមអន្គអញក្ស័យ ក្នុងព្រៃព្រឹក្សា ឥតអ្នកឯណា
មួយមកយន់យល់ ។
ឥឡូវអន្គអញ បិត្តបង់បំពេញ បារមីផ្ដេកផ្ដល់
ឲ្យបានត្រាស់ថ្វាត់ នាំសត្វសែនសល់ ដោមដាក់តំកល់
ដល់ត្រើយនិព្វាន ។
បើអញក្ស័ណក្ស័យ កណ្ដាលព្រឹក្សព្រៃ សូមឲ្យសមរសោះខាន

១-ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ២-បៀតបៀន, យាយី ។



ឃ្លាឃ្លាតបំណង ប៉ុនប៉ងពុំបាន បំពេញសីលទាន
ដូចចិត្តប្រាថ្នា ។
ហេតុដ្បិតឯកោ អន្គអនាថោ មុតិតកំព្រា
ឥតសាច់សន្តាន ឥតមានករិយា ថែទាំរក្សា
ស្ងួនគ្រងសព្វថ្ងៃ ។
អ្នកគិតទៅសព្វ គ្រប់ហើយរើងថប់ ថប់ពន់ពេកក្រៃ
ដ្បិតនៅម្នាក់ឯង កណ្ដែងក្នុងព្រៃ ព្រួយព្រះហឫទ័យ
ពេកពន់ប្រមាណ ។
គេជះសម្ភារ គោតគុលកុមារ ពូជពង្សពុទ្ធញាណ
ការក្រើកទៅដល់ មណ្ឌលពិមាន ទេនទិព្វទីឋាន
សម្ដេចឥន្ទ្រា ។
ស្ដេចបើកទិព្វចក្ខុ យន់យល់ជៀនជាក់ ជ្រួតជ្រាបថែថា
គោតគុលកុមារ ពិសាលសោភា ពុំមានករិយា
ជាគូសម្ពន្ធ ។
ទើបស្ដេចគិតថា នាងទេពធីតា ដែលអញនិមន្ត
ចុះទៅមនុស្សលោក យោនយកបដិសន្ធិ នៅនាតំបន់

សត្តកុជបុរី ។

អាស្រ័យនៅនា ក្នុងទ្វីប ព្រះអគ្គមហេសី

ស្តេចសត្តកុដពជ អំណាចរឹទ្ធិ គ្រប់គ្រងបុរី

ពលពាលសេនា ។

រីនគរនោះ ជាទីទួលកោះ កណ្តាលជលសា

ទំហំនគរ បវររដ្ឋា បួនយោជន៍គណនា

រាស្ត្រផងសប្បាយ ។

ទៀបនឹងបុរី ពារាណសី គណនាចម្ងាយ

យោជន៍សាមសិបប្រាំ ពិតពុំឃ្លាតឆ្ងាយ គេគ្រាឈ្មួញឆ្ងាយ

ចូលជួញឥតអាក់ ។

រីឯធីតា សោឡសវស្សា(១) កបទូវនរល័ក្ខណ៍

ដូចទេពអប្សរ បវរស្នួតិស័ក្តិ ព្រះខាត់ព្រះភ័ក្ត្រ

ដូចចន្ទបូណ៌មី ។

## បទភុជង្គលីលា

ព្រះឥន្ទ្រទេវិន្ទ្រធិបតី(២) គន់គិតពិតពី- ចារណាយល់យល់ ។

១ មានអាយុ១៦ឆ្នាំ ។ ២-កំពូលជាធំលើសលែងទេវតា ធំជាស្តេចនៃទេវតា ។



ទេវីស្រស់ស្រីនិមិល គាប់គួរតំកល់ ឲ្យជាភរិយា ។

ភោគកុលនិមិលកុមារ ជាគូផងគ្នា កុំឲ្យឃ្លៀងឃ្លាត ។

គិតស្រេចសម្តេចនរនាថ ចេញចាកប្រាសាទ សួគ៌ត្រៃត្រិង្ស ។

ហោះដល់មណ្ឌលសីមា សត្តកុដពជមហា- នគររម្យរ័ត្ន ។

ព្រះសូរបេទ្ធូលទៅថ្វាត់ ឋាវៃហមហាក្សត្រ សត្តកុដពជា ។

យើងមកសួរកេប្រាថ្នា សូមរាជធីតា បុត្រមហេសីធំ ។

យើងនឹងយកទៅផ្សំផ្សំ នឹងប្រុសឧត្តម មួយមានចេស្តា ។

ជាគូនៃបនិត្យស្នេហា អ្នកនឹងបានជា ក្សត្រថ្លៃថ្កើងថ្កាន ។

សោយពង្សអំណាចហៅហាន គ្រប់គ្រងពារា- ណសីនគរ ។

ទើបមហាក្សត្របវរ សោមនស្សសាទរ ទៀងទូលទៅថា ។

សក្កាទេវរាជា ទ្រង់ព្រះប្រាថ្នា ចង់បានបុត្រី ។

យកទៅលំនៅទូរទី(១) ឲ្យមានស្វាមី ខ្ញុំសោតព្រមថ្វាយ ។

ព្រះឥន្ទ្រទេវិន្ទ្រតណ្ណកយ សោមនស្សសាយ ត្រេកអរពេកក្តាត់ ។

ទៅពបីយកស្រីរ័ត្ន នានាំហោះថ្វាត់ ទៅទិចម្ការ ។

ដល់ស្រេចទើបស្តេចកាឡា និម្មិតកើតជា ចង់ស្បែកមួយធំ ។

១. ទីឆ្ងាយ ។

ប្រមាណថង់មានទំហំ ប៉ុនផ្លែឃ្លោកធំ មូលដូចស៊ុតមាន់ ។
ដាក់ទ្រព្យសម្រាប់គ្រប់គ្រាន់ គ្រឿងទិព្វសុវណ្ណ ភោជនាហារ ។
ទើបផ្តាំថែតាំកិច្ចការ ថាហៃកញ្ញា រ័ត្នកជបុត្រី ។
ចិន្តាប្រាថ្នាអ្វី ។ ចូរយកអំពី ក្នុងថង់នេះបាន ។
ដូចចិត្តគន់គិតរះព្យាន បរិបូណ៌ពុំខាន បានដូចប្រាថ្នា ។
ស្តេចដាក់វល័ក្ខណ៍ធីតា ក្នុងថង់ថ្ងៃថ្លា ហើយអធិដ្ឋាន ។
ឲ្យតែសត្វក្តិតប្តាន មកព្រុសឲ្យបាន ជឹងដល់កុមារ ។
ផ្សងស្រេចសម្តេចឥន្ទ្រា ស្តេចហោះលីលា ត្តោះទៅសួគ៌ឋាន ។

## បទកាកគតិ

កាលនោះថ្ងៃស ស្រង់ស្រាក់ទៅមក ផ្ទើរហិតដោយដាន
យង់យល់ថង់ស្បែក ចំឡែកមែនមាន អស្ចារ្យនាឋាន
ខេត្រនាងបក្ការ ។
ក្តែឈប់ឈរព្រុស នៅនាឋាននោះ រំពង់សោះសា
លូព្រស័ព្ទដល់ ភោគគុលកុមារ ទើបអ្នកយាត្រា
ទៅទើបយេង់យល់ ។
ថង់ស្បែកទំហំ ប៉ុនផ្លែឃ្លោកធំ ជាអស្ចារ្យសល់



អ្នកយកថង់នោះ វិលត្រោះមកដល់ ដាក់លើមណ្ឌល
ខាងទិទ្រា ។
លុះព្រឹកឡើងវិញ អ្នកចរចាកចេញ ទៅធ្វើចម្ការ
ក្រោយនោះក្សត្រី ទេវីថ្ងៃថ្លា យល់កុមាព
អ្នកចរចេញទៅ ។
ទើបវរទេវី ចរចេញអំពី ថង់មកឯក្រៅ
កែអំបោសបោស ទីឋានលំនៅ ទើបនាងដើរទៅ
ដងទឹកគង្គា ។
យកមកដាក់ពាង ពោរពេញហើយនាង រៀបភោជន៍ជា
អាហារទិព្វទេស ពិសេសពិសា ទុកឲ្យព្រះមហា
បុរសរ័ត្ន ។
ទើបនាងវរវង្ស វិលចូលទៅក្នុង ថង់ស្បែកវិញថ្ងាត់
ពួនពីងសម្ងំ ជ្រងំស្ងប់ស្ងាត់ ពុំឲ្យឮមាត់
ដឹងដល់កុមារ ។
ឯព្រះពោធិ៍ ចាំងជម្រះទី ឋានចម្ការកាល-
ថ្ងៃខ្ពស់ឡើងបាន លុះឃ្លានអាហារ អ្នកត្រាច់ត្រកាល